# រឿង សុបិនកុមារ



សៀវភៅរូបភាពសម្រាប់កុមារ លេខ ១០៤

# រឿង សុបិនកុមារ

ដកស្រង់ចេញពីសៀវភៅ រឿងសុបិនកុមារ   បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ

រៀបរៀងដោយ ជិន យ៉ាហាន
គូររូបភាពដោយ ចាន់ ពិសី
ត្រួតពិនិត្យដោយ បណ្ឌិត កែវ ណារុំ   អនុបណ្ឌិត   ហ៊ី ចិន្តា

សៀវភៅនេះ   បានទទួលការអនុញ្ញាតឲ្យបោះពុម្ពពីក្រសួងអប់រំយុវជន និងកីឡា តាមប្រកាសលេខ ៤៤៣ អយក ប្រក ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១   ដើម្បីប្រើប្រាស់ជាប្រភេទសៀវភៅអានបន្ថែមនៅតាមសាលារៀនចំណេះទូទៅ ។



បោះពុម្ពលើកទី ១        ចំនួន ៣ ០០០ ច្បាប់
ISBN: 978-99950-56-35-3
©រក្សាសិទ្ធិដោយអង្គការសេដ្ឋីស្ម័គ្រចិត្ត (SVA)
បោះពុម្ពនៅរោងពុម្ព Digital Advertising
ភ្នំពេញ   ខែមីនា ឆ្នាំ ២០១១

កាលពីសម័យយូរលង់ណាស់មកហើយ នៅនគរសាវត្ថី មានគ្រួសារមួយ ពីរនាក់ប្ដីប្រពន្ធ ប្រកបរបរនេសាទ និងបរបាញ់សត្វដើម្បីចិញ្ចឹមជីវិត ។ ស្ត្រីជាភរិយា កាលបើមានគភ៌ នាងមានអាការៈរហិតរហៃអស់កម្លាំង ញាប់ញ័រ ក្នុងប្រាណខុសធម្មតា ។ រាត្រីមួយ នាងយល់សប្តិថា នាងបានចេញពីផ្ទះ ដើម្បីទៅរកអុសក្នុងព្រៃ គ្រាន់នឹងលក់ ។





លុះដើរចូលក្នុងព្រៃជ្រៅទៅៗ នាងក៏វង្វេងផ្លូវ ។ ដោយភ័យពេក នាងស្រែករកប្តី ។ បន្ទាប់មក នាងបានដើរចេញផុតពីព្រៃធំនោះ ហើយបានឃើញសមុទ្រធំដ៏ល្វឹងល្វើយ ធ្វើឱ្យនាងកាន់តែភ័យរន្ធត់ខ្លាំងឡើង ។ នាងក៏អង្គុយយំ ហើយនិយាយថា "ឱ លោកអ្នកណាអើយ! ជួយបង្ហាញផ្លូវខ្ញុំ ឱ្យបានវិលត្រឡប់ទៅផ្ទះវិញផង" ។







មួយរំពេចនោះ ស្រាប់តែ មានតាឥសីហោះនៅលើអាកាស ដៃកាន់កែវមណីរត្នដែលមានរស្មីចែងចាំង យកមកដាក់លើបាតដៃនាង ហើយចង្អុលបង្ហាញផ្លូវ ឱ្យនាងត្រឡប់ទៅវិញ ។ នៅពេលបានកែវមណីរត្នហើយ នាងក៏រកឃើញផ្លូវទៅផ្ទះ រួចបានជួបប្ដីដូចចិត្តប្រាថ្នា ។ នាងភ្ញាក់ដឹងខ្លួនវិញ នាពេលទៀបភ្លឺ ។



ព្រឹកឡើង ភរិយា និងស្វាមីក៏មីម្នារកចេក ម្លូស្លា ទៀនធូប និងបេះផ្កាភ្ញី ដើម្បីទៅរកគ្រូទស្សន៍ទាយឱ្យកាត់សប្តិ ។ លុះនាងរៀបរាប់ដំណើរយល់សប្តិសព្វគ្រប់ហើយ គ្រូទស្សន៍ទាយប្រាប់នាងថា "សុបិននោះ ល្អវិសេសវិសាលណាស់" ។



"នាងប្រាកដជាមានគភ៌ ហើយប្រសូតបានកូនប្រុសដ៏ល្អឧត្តមក្រៃលែង ជាទីពឹងរបស់ញាតិទាំងឡាយផង"។ ពេលបានស្ដាប់ហើយ នាងត្រេកអរណាស់ ក៏លើកគ្រឿងតង្វាយជូនគ្រូទាយ រួចត្រឡប់មកផ្ទះវិញ ។



ចាប់ពីពេលនោះមក បុរសជាប្តីយកចិត្តទុកដាក់មើលថែភរិយារហូតដល់នាងគ្រប់ខែ ។ នាងក៏ប្រសូតបានកូនប្រុសម្នាក់ដ៏មានសម្បុរថ្លៅស្អាត ។ នាងនិងស្វាមី បានដាក់ឈ្មោះកូនថា "សុបិនកុមារ" ។





ថ្វីត្បិត សុបិនកុមារជាកូនអ្នកនេសាទ ប៉ុន្តែ សុបិនកុមារ មិនដែលធ្វើនេសាទ ឬប្រមាញ់ប៉ះពាល់ជីវិតសត្វទេ ។ លុះ សុបិនកុមារអាយុបាន៧ ឆ្នាំ បុរសជាឪពុកបានធ្វើមរណកាលទៅ ហើយបានកើតជាប្រេត ព្រោះកាលនៅរស់ គាត់ពុំបានគោរពតាមព្រះធម៌របស់ព្រះពុទ្ធ ពុំបានធ្វើបុណ្យទាន ពុំបានរក្សាសីល ហើយរវល់តែនឹងការបរបាញ់ និងសម្លាប់សត្វ ។









សុបិនកុមារក្លាយជាក្មេងកំព្រាឪពុក រស់នៅតែជាមួយម្តាយ ហើយ តែងតែសុំម្តាយទៅលេងនៅឯវត្ត ដោយជួយបោសសំអាតទីអារាម ជម្រះស្មៅ ដាំទឹក បម្រើព្រះសង្ឃពុំដែលខ្ជិលឡើយ ។



លុះអាយុបាន ១៦ ឆ្នាំ **សុបិនកុមារ**នឹកចង់បួស ក៏ទៅសុំព្រះសង្ឃឱ្យបំបួសខ្លួន តែព្រះសង្ឃប្រាប់ឱ្យ**សុបិនកុមារ**ទៅសុំម្ដាយសិន ។ ម្ដាយ**សុបិនកុមារ** ក៏បានឃាត់**សុបិនកុមារ** មិនចង់ឱ្យកូនឃ្លាតឆ្ងាយ ដោយសារនឹកអាល័យកូនគាត់ ព្រោះមានកូនតែម្នាក់ ។ តែទោះបីជាម្ដាយយំ និងឃាត់កូនយ៉ាងណាក៏ដោយ ក៏មិនអាចឃាត់កូនបានឡើយ ។



ឯនៅឋាននរកវិញ យមរាជកំពុងចាត់យមបាល ៤នាក់ ដើរទៅរកមើលមនុស្សណាដែលពុំបានរក្សាសីល ធ្វើបុណ្យដាក់ទាន មានចិត្តកំណាញ់ឫស្យា ទោះចាស់ក្តី ក្មេងក្តី ទោះប្រុសក្តី ស្រីក្តី ត្រូវចារឈ្មោះក្នុងបញ្ជីស្បែកឆ្កែ ហើយចាប់ចង យកមកទម្លាក់ក្នុងភ្លើងនរក ។





ពេលយមបាលរំជ្រែកដីឡើងមកឋានមនុស្ស  ក៏បានឃើញម្តាយ **សុមិនកុមារ** ដែលកំពុងសម្រាន្តលក់ក្នុងព្រៃ  ក្រោយពេលកាប់អុសរួច ។ យមបាលពិនិត្យមើលបញ្ជីឃើញថានាងពុំដែលបានរក្សាសីល  ក៏ចាប់គាត់ ហើយបណ្ដើរយកទៅឋានយមរាជ ។

យមរាជចាត់អ្នកកត់ត្រាផ្ទៀងមើលបញ្ជីឈ្មោះ ឃើញថានាងជាស្រីមានបាប ក៏សួរថា: តើនាងបានធ្វើបាប ឬបុណ្យអ្វីខ្លះ ចូរនិយាយឱ្យត្រង់មក? ។ ដោយហេតុមានបាប ព្រោះបានឃាត់កូនមិនឲ្យទៅបួស ម្ដាយ**សុបិនកុមារ** ក៏វង្វេងស្មារតី ស្រដីថា ខ្លួនខ្ញុំជាស្រី តាំងពីក្មេងខ្ចីមកពុំបានដឹងថា អ្វីជាបាប បុណ្យបាន ។





ទោះបី អ្នកសួរចម្លើយ ខឹងដាល់តប់យ៉ាងណាក៏នាងនៅតែឆ្លើយថាពុំដឹង ។ អ្នកកត់ត្រាកត់ពាក្យទាំងនេះទៅសូត្រប្រាប់យមរាជ ។ យមរាជត្រាស់បង្គាប់ថា ឱ្យយកនាងចេញទៅ បោះទៅក្នុងភ្លើងនរក ។



យមបាលក៏ចាប់នាងចងបណ្ដើរទៅរកភ្លើងដែលកំពុងឆេះ ។ លុះឃើញពន្លឺភ្លើង នាងដណ្ដឹងសួរយមបាលថា តើអ្វីនេះម្ដេចក៏ភ្លឺច្រាលដូចជា ចីពរកូនខ្ញុំ? ។ យមបាលកំពុងក្រេវក្រោធផង ក៏ទះមាត់នាង ស្ដីឱ្យនាងថា "កាលដើមម្ដេចមិនស្រដី លុះឃើញអគ្គិប្រែជាថាចីពរកូនឯង?" នាងបានស្រែកទ្រហោយំខ្លោចៗ ហៅរកកូនឱ្យជួយ ។



ពេលយមបាលបោះនាងចូលទៅក្នុងភ្នក់ភ្លើង ស្រាប់តែផ្កាឈូកមាសប៉ុនកង់រាជរថផុសឡើង ទ្រនាងជាប់ ។ យមបាលខឹងណាស់ កន្ត្រាក់នាងទម្លាក់ទៅក្នុងរណ្ដៅភ្លើងមួយទៀតដែលមានទំហំមួយពាន់យោជន៍ ផ្កាឈូកមាសក៏ផុសឡើងទ្រនាងទៀត ។ ភ្លាមនោះ យមបាលក៏លោតទៅចាប់ជើងនាងទាញទម្លាក់ទៅក្នុងរណ្ដៅភ្លើងមួយទៀតដែលមានទំហំមួយម៉ឺនយោជន៍ ផ្កាឈូកមាសផុសឡើងទ្រនាងជាប់ទៀត ។







ឃើញដូច្នោះ យមបាលភិតភ័យ ក្រាបបង្គំ ហើយដោះលែងនាងមកវិញ ។ ម្ដាយ**សុបិនកុមារ**ភ្ញាក់ដឹងខ្លួន ក្រោកឡើងមីម្នាលើកអុសទូលដើរទៅវត្ត ដើម្បីនិយាយទូលកូន ។ នៅពេលទៅដល់វត្ត នាងបានទូលសាមណេរឱ្យវិលត្រឡប់មកភូមិវិញ ដើម្បីធ្វើពិធីជញ្ជាត់ព្រលឹង រួចសឹមធ្វើពិធីបំបួសសាជាថ្មីដោយចិត្តជ្រះថ្លា ។



កាលខាងក្រោយមក សាមណេរសុបិនសង្វាតបំពេញមគ្គផលយ៉ាងត្រឹមត្រូវ រួមទាំងបិណ្ឌបាតចិញ្ចឹមមាតា ហើយចម្រើនភាវនាទៅរំដោះឪពុក ។ លុះម្តាយអស់សង្ខារក៏បានទៅកើតនៅឋានសួគ៌ ។ ឯឪពុកក៏បានរំដោះផុតទុក្ខភ័យពីឋានប្រេត ទៅកើតនៅឋានសួគ៌ដែរ ។ នេះបណ្តាលពីអំណាចអានិសង្សរបស់កូនប្រុសដែលបានបួសក្នុងសំណាក់ព្រះពុទ្ធសាសនា ។

ចប់





អង្គការសន្តិស្ម័គ្រចិត្ត

Shanti Volunteer Association

*Move forward, hand in hand.*

ISBN: 978-99950-56-35-3

9789995056353